# ហិង្សា និង ទោសៈ

ហិង្សា និង ទោសៈ វាខុសគ្នា។ ជួនកាល ហិង្សា វាអាចទុកជាពេញសិទ្ធិ បើជាអំពើតស៊ូ ឬប្រឆាំងនឹងអំពើសង្កត់សង្កិន។ កេរ្តិ៍តំណែល នៃអំពើហិង្សាពេញសិទ្ធិ ធ្លាប់កើតមាននៅស្រុកខ្មែរ ក្នុងសម័យទ័ពយួនកាន់កាប់ នៅក្នុងរាជ្យ ព្រះអង្គក្សត្រី ម៉ី (១៨៣៤-១៨៤១) មាន ទ្រឿង មិញយ៉ាង ជាមេទ័ពធំយួន ពាក់ងារជា អុង ទ្រឿងគុន។ មេទ័ពយួននេះ ឃោរឃៅណាស់ ធ្វើបាបខ្មែរ បៀតបៀនព្រះពុទ្ធសាសនា បង្ខំអោយមន្ត្រីរាជការខ្មែរ ស្លៀកពាក់ជាមន្ត្រីយួន។ ដោយទ្រាំនឹងការសង្កត់សង្កិននេះពុំបាន មន្ត្រីខ្មែរ និង អាណាប្រជានុរាស្ត្រគ្រប់ខែត្រ គិតឃើញដូចគ្នា ដូចសន្មត់ ងើបបះបំបោរ ជាកងទ័ព ប្រឆាំងនឹងយួន លើកដេញកាប់ទាហានយួនតែមួយយប់ នាំអោយទ័ពយួនរត់ខ្ចាត់ខ្ចាយអស់។

ទោសៈ ជាកំហឹងក្រេវក្រោធ និង សេចក្តីច្រណែន ផ្កាប់មុខ។ អំពើនេះ ធ្លាប់កើតមានដែរនៅស្រុកខ្មែរ គឺនៅសម័យ ពួកខ្មែរក្រហមដឹកនាំជាតិ (១៩៧៥-១៩៧៩)។ ពួកអ្នកដឹកនាំនោះ នាំគ្នាធ្វើបដិវត្ត នៃសមភាពនិយម និង ប្រានចោល នូវបុព្វសិទ្ធិនៃវណ្ណៈសិប្បនិម្មិត ដែលនាំអោយខ្មែរ ជាងពីលាននាក់ ស្លាប់បាត់បង់ជីវិត។ របបនៅភ្នំពេញសព្វថ្ងៃ បន្តប្រព្រឹត្តអំពើទោសៈផ្កាប់មុខដដែល ចំពោះជនខ្មែរទាំងឡាយ ដែលប្រឆាំងនឹងខ្លួន។ ដូច្នេះ ជម្រើសជំនួស នៃរបបខ្មែរក្រហម គ្មាននោះឡើយ ព្រោះពួកអ្នកដឹងនាំសព្វថ្ងៃ ជាខ្មែរក្រហមតែមួយ៕

ឧប សៅ សង្ហា គំនិត ១៦ មិថុនា ២០១៩